**កំណត់សម្គាល់អំពីការសិក្សា:**ដើម្បីបញ្ចប់ម៉ូឌុលលនេះ អ្នកប្រើពេលសរុបប្រហែលពីរម៉ោង ។ បន្ទាប់ពីផ្នែកសំខាន់នីមួយៗ អ្នកអាចស្វែងរកទីកន្លែងដ៏សមរម្យសម្រាប់អ្នកដើម្បីផ្អាកការសិក្សារបស់អ្នកសិន។

## ម៉ូឌុល ៦: គំនូរឧស្សាហកម្ម

**គោលដៅ:** នៅចុងបញ្ចប់នៃម៉ូឌីលនេះ អ្នកនឹងអាច ៖

១- ពន្យល់ប្រមាណ៥០ពាក្យថាតើអ្វីទៅជាគំនូរឧស្សាហកម្ម

២-ពន្យល់អពីលក្ខណៈខុសគ្នារវាងកិច្ចការពារគំនូរឧស្សាហកម្ម និងកិច្ចការពារម៉ាក និងប្រកាសនីយបត្រតក្កកម្ម

៣-វាយពីអត្ថប្រយោជន៍នៃកិច្ចការពារគំនូរឧស្សាហកម្ម សម្រាប់

- ម្ចាស់គំនូរឧស្សាហកម្មដែលបានការពារ
- អ្នកប្រើប្រាស់ផលិតផល
- សេដ្ឋកិច្ច

៤- ពិពណ៌នាអំពីវិធីដែលគំនូរឧស្សាហកម្មមួយអាចត្រូវបានការពារ។

### សេចក្តីផ្តើម

ម៉ូឌុលនេះពិពណ៌នាអំពី កិច្ចការពារទម្រង់មួយនៃកម្មសិទ្ធិបញ្ញាដែលមានឈ្មោះថាគំនូរឧស្សាហកម្ម។ ទស្សនៈទានស្តីពីគំនូរឧស្សាហកម្ម នឹងត្រូវបានពិពណ៌នារួមជាមួយអត្ថប្រយោជន៍ដែលអាចទទួលបានពីកិច្ចការពារគំនូរឧស្សាហកម្ម ។

### តើគំនូរឧស្សាហកម្មគឺជាអ្វី ?

គំនូរឧស្សាហកម្មមួយជាទិដ្ឋភាពនៃវត្ថុមួយ ដែលមានប្រយោជន៍ដែលមានលក្ខណៈគ្រឿងលម្អឬសោភ័ណភាព ។ គំនូរឧស្សាហកម្មអាចមានលក្ខណៈជារូបរាងបីជ្រុងដូចជារូបរាងឬផ្ទៃនៃវត្ថុ ឬលក្ខណៈពិសេសរូបរាងពីរជ្រុងដូចជាគំនូរ ខ្សែបន្ទាត់ ឬពណ៌ ។

គំនូរឧស្សាហកម្មត្រូវបានអនុវត្តចំពោះផលិតផលឧស្សាហកម្ម ឬសិប្បកម្មជាច្រើនចាប់ពីនាឡិកាដៃ គ្រឿងអលង្ការ ម៉ូដសំលៀកបំពាក់ ឬវត្ថុល្អប្រណិតផ្សេងៗទៀតទៅដល់សំភារៈ

©WIPO/OMPI

ឧស្សាហកម្ម ឬថ្នាំពេទ្យចាប់ពីប្រដាប់ប្រដាប្រើប្រាស់នៅក្នុងផ្ទះ គ្រឿងសង្ហារឹម និងគ្រឿងអគ្គីសនីទៅដល់រថយន្ត និងរចនាសម្ព័ន្ធនៃស្ថាបត្យកម្ម ចាប់ពីទំនិញប្រើប្រាស់ និងគំនូរវាយនភណ្ឌទៅដល់ឧបករណ៍កំសាន្ត ដូចជាប្រដាប់ប្រដាក្មេងលេង និងឧបករណ៍ចិញ្ចឹមសត្វ ។



.

ឧទាហរណ៍:រូបរាង ឬទ្រង់ទ្រាយនៃកៅអី ទូរស័ព្ទ រថយន្ត កំព្យូទ័រ យន្តហោះ ទូរទស្សន៍ នាឡិកាដៃ ម៉ាស៊ីនថតរូប ។ល។

ភាគនៃសម្លេងទី១: ម៉ាកជាទូទៅជាសញ្ញាដែលមើលឃើញដែលបំពាក់ទៅលើទំនិញ ឬប្រើប្រាស់ទៅលើការផ្តល់សេវាកម្មរីឯប្រកាសនីយបត្រតក្កកម្ម ត្រូវបានប្រើប្រាស់ដើម្បីការពារតក្កកម្មដែលបង្កើតឡើងពីការច្នៃប្រឌិត។ ម៉ាកនិងគំនូរឧស្សាហកម្មមានលក្ខណៈខុសគ្នាដូចម្តេចខ្លះ?

គំនូរឧស្សាហកម្ម ខុសគ្នាជាចម្បងពីម៉ាកដោយសារតែគំនូរឧស្សាហកម្មបង្កើតឡើងដោយរូបរាងផលិតផល ដែលមិនតម្រូវឱ្យមានលក្ខណៈញែកដាច់ (ល័ក្ខខ័ណ្ឌតម្រូវចាំបាច់នៃម៉ាក)។ ទោះបីជាម៉ាកអាចរួមមានរាល់ប្រភេទនៃសញ្ញាដែលមើលឃើញ ដែលអាចឬមិនអាចមានលក្ខណៈជាសោភណ្ឌភាពក៏ដោយ ត្រូវមានលក្ខណៈកញែកដាច់ ដោយសារម៉ាកត្រូវតែអាចសម្គាល់លក្ខណៈខុសគ្នានៃទំនិញនិងសេវារបស់សហគ្រាសមួយទៅសហគ្រាសមួយ ។ ហេតុដូច្នេះមុខងារ និងការបង្ហាញភស្តុតាងស្តីពី កិច្ចការពារគំនូរឧស្សាហកម្មនិងម៉ាកពិតជាមានលក្ខណៈខុសគ្នាខ្លាំងណាស់ ។

កម្មវត្ថុនៃកិច្ចការពារគំនូរឧស្សាហកម្មខុសប្លែកពីកម្មវត្ថុ នៃកិច្ចការពារប្រកាសនីយបត្រ

©WIPO/OMPI

តក្កកម្ម  ជាបឋមដោយសារតែគំនូរឧស្សាហកម្មពាក់ព័ន្ធនឹងរូបរាងផលិតផល និងមិនត្រូវបានកំណត់ដោយភាពចាំបាច់ផ្នែកបច្ចេកទេសឬមុខងារឡើយ។ ផ្ទុយទៅវិញ កម្មវត្ថុនៃកិច្ចការពារប្រកាសនីយបត្រតក្កកម្មកំណត់ដោយមុខងារនៃផលិតផល ឬដំណើរការព្រោះផលិតផលនោះត្រូវតែជាតក្កកម្ម។

**សំណួរវាយតម្លៃខ្លួនឯង (SAQ)**

**SAQ 1:  តើទម្រង់នៃកិច្ចការពារមួយណាដែលសមស្របសម្រាប់វត្ថុដូចខាងក្រោម**

**ក) ប៉ាន់តែ**



**ខ) ទម្រង់ថ្មីនៃម៉ូទ័រអេឡិចត្រូនិច**

**គ) ឡូហ្គូនៃសាកលវិទ្យាល័យ (Open University)**

The Open

University

សរសេរចម្លើយរបស់អ្នក នៅត្រង់នេះ

ចុចត្រង់នេះដើម្បីមើលចម្លើយ

**SAQ 1: ចម្លើយ**

ក)   ទម្រង់ដែលសក្តិសមនៃកម្មសិទ្ធិបញ្ញាដែលមានក្នុងប៉ាន់តែគឺ  តាមរយៈកិច្ចការពារគំនូរឧស្សាហកម្ម ។ ប៉ុន្តែប្រសិនបើប៉ាន់តែមានវីធីផុងតែថ្មីប្រកបដោយភាពច្នៃប្រឌិតនោះ ប៉ាន់តែនោះអាចមានលទ្ធភាពការពារសមាសធាតុនោះដោយប្រកាសនីយតក្កកម្ម ។

©WIPO/OMPI

ខ) ទម្រង់ដែលសក្តិសមគឺការប្រើប្រាស់ប្រកាសនីយបត្រតក្កកម្ម ។

គ) សញ្ញានេះភាគច្រើនអាចត្រូវបានប្រើប្រាស់ជាម៉ាកហេតុដូច្នេះ ហើយកិច្ចការពារម៉ាកអាចជាវិធីល្អបំផុត ។

## មូលហេតុដែលត្រូវការពារគំនូរឧស្សាហកម្ម ?

តាមរយៈកិច្ចការពារគំនូរឧស្សាហកម្ម ម្ចាស់គំនូរឧស្សាហកម្មត្រូវបានផ្តល់សិទ្ធិប្រឆាំងនឹងការថតចម្លងឬការត្រាប់តាមដែលគ្មានការអនុញ្ញាតដោយភាគីទី៣ ។ម្យ៉ាងទៀតម្ចាស់គំនូរឧស្សាហកម្មដែលទទួលបានកិច្ចការពារនោះត្រូវមានសិទ្ធិរាំងភាគីទី៣មិនឲ្យផលិត លក់ ឬនាំចូលផលិតផលដែលមានឬជាគំនូរដែលថតចម្លងពីគំនូរដែលបានការពារ ។

ដោយសារគំនូរឧស្សាហកម្ម គឺជាទិដ្ឋភាពនៃផលិតផលដែលមានសោភ័ណ្ឌភាពនិងមានភាពទាក់ទាញគំនូរឧស្សាហកម្មមាននាទីបន្ថែមតម្លៃសេដ្ឋកិច្ចលើផលិតផល និងជួយសម្រួលដល់ការធ្វើទីផ្សារនិងការធ្វើពាណិជ្ជកម្ម។

ដើម្បីការពារតាមច្បាប់ជាតិ គំនូរឧស្សាហកម្មមួយត្រូវតែមានរូបរាងច្បាស់លាស់។ គំនូរឧស្សាហកម្មមិនការពារលក្ខណៈផ្នែកបច្ចេកទេសណាមួយនៃទំនិញ ដែលត្រូវបានគេប្រើប្រាស់នោះឡើយ ។

ភាគនៃសម្លេងទី២: កិច្ចការពារគំនូរឧស្សាហកម្មពិ តជាមានអត្ថប្រយោជន៍ដល់ម្ចាស់គំនូរឧស្សាហកម្មប៉ុន្តែតើកិច្ចការពារនេះផ្តល់អត្ថប្រយោជន៍អ្វីផ្សេងទៀតដែរឬទេ?

បាទ/ចាស អ្នកនិយាយត្រូវណាស់ ម្ចាស់គំនូរឧស្សាហកម្មទទួលបានអត្ថប្រយោជន៍តាមរយៈការអភិវឌ្ឍឧស្សាហកម្មនៃផលិតផលរបស់ខ្លួន ហើយកិច្ចការពារនេះជួយធានាចំពោះប្រាក់ចំណេញពីការវិនិយោគទៀតផង ។

©WIPO/OMPI

ប៉ុន្តែអ្នកប្រើប្រាស់និងសាធារណជនជាច្រើនក៏ទទួលបានអត្ថប្រយោជន៍ផងដែរដោយសារកិច្ចការពារគំនូរឧស្សាហកម្មធ្វើឱ្យមានការប្រកួតប្រជែងដោយស្មើភាព និងការធ្វើពាណិជ្ជកម្មដោយស្មោះត្រង់ ជួយលើកទឹកចិត្តដល់ការកែច្នៃថ្មី ដែលនាំឱ្យមានផលិតផលជាច្រើនដែលមានភាពទាក់ទាញនិងប្រកបដោយសោភ័ណភាព។

កិច្ចការពារគំនូរឧស្សាហកម្មបានបញ្ចូលនូវភាពច្នៃប្រឌិតផងដែរ ទៅក្នុងផ្នែកឧស្សាហកម្មនិងផលិតកម្មដែលចូលរួមចំណែកនៅក្នុងការពង្រីកសកម្មភាពពាណិជ្ជកម្ម និងលើកកម្ពស់ផលិតផលថ្នាក់ជាតិដែលមានសក្តានុពលនៅក្នុងការនាំចេញ ។

ដូច្នេះកិច្ចការពារគំនូរឧស្សាហកម្មផ្តល់ផលប្រយោជន៍ដល់ម្ចាស់សិទ្ធិ អ្នកប្រើប្រាស់និងសេដ្ឋកិច្ចជាទូទៅ។ លក្ខណៈពិសេសមួយទៀតរបស់គំនូរឧស្សាហកម្មគឺថាគំនូរឧស្សាហកម្មមានភាពសាមញ្ញនិងមិនចំណាយច្រើនក្នុងការអភិវឌ្ឍន៍ និងការពារ ។ ហេតុដូច្នេះហើយទាំងសហគ្រាសខ្នាតតូចនិងមធ្យម សិល្បៈករ និងសិប្បករអាចមានលទ្ធភាពបង្កើតនិងការពារបានគំនូរឧស្សាហកម្មទាំងនៅក្នុងប្រទេសឧស្សាហកម្ម និងប្រទេសដែលកំពុងអភិវឌ្ឍ ។

## តើគំនូរឧស្សាហកម្មអាចត្រូវបានការពារ យ៉ាងដូចម្តេចខ្លះ ?

នៅក្នុងប្រទេសជាច្រើនគំនូរឧស្សាហកម្មមួយត្រូវតែចុះបញ្ជីដើម្បីទទួលបានកិច្ចការពារតាមច្បាប់ ស្តីពី គំនូរឧស្សាហកម្ម។ តាមវិធានទូទៅ ដើម្បីចុះបញ្ជី គំនូរត្រូវតែ ´ថ្មី` ឬ ´ដើម` ។ បច្ចុប្បន្នភាពថ្មី ឬភាពដើមអាចមានលក្ខណៈខុសគ្នាពីប្រទេសមួយទៅប្រទេសមួយទៀត ហើយដំណើរការចុះបញ្ជី ក៏មានភាពខុសគ្នាពីប្រទេសមួយទៅប្រទេសផងដែរ។ជាពិសេសបញ្ហានេះអាចមានការពាក់ព័ន្ធថាតើមានការត្រួតពិនិត្យឬគ្មានការត្រួតពិនិត្យទម្រង់បែបបទនិងខ្លឹមសារនៃពាក្យស្នើសុំចុះបញ្ជីគំនូរនោះឬទេ ជាពិសេសក្នុងការកំណត់នូវភាពថ្មី ឬភាពដើម ។

គំនូរឧស្សាហកម្មត្រូវតែអាចផលិតឡើងវិញតាមមធ្យោបាយឧស្សាហកម្ម ( ការអនុវត្តក្នុងវិស័យឧស្សាហកម្ម )។គំនូរឧស្សាហកម្ម ក៏អាចប្រើប្រាស់បានជាមួយផលិតផលដែលមានទម្រង់ពីរខ្នាត ឬបីខ្នាត ។



©WIPO/OMPI

ជាគោលការណ៍ គំនូរឧស្សាហកម្មត្រូវបានបោះពុម្ពផ្សាយនៅមុនឬក្រោយចុះបញ្ជី។ នេះអាស្រ័យលើច្បាប់ជាតិ ជួនកាលអាស្រ័យលើការសម្រេចរបស់អ្នកស្នើសុំ ។

លើសពីនេះទៅទៀតគួរចងចាំថា ការចុះបញ្ជីគំនូរឧស្សាហកម្មមិនមែនជាវិធីតែមួយក្នុងកិច្ចការពារនោះទេ។ គំនូរឧស្សាហកម្មអាចត្រូវបានការពារក្រោមច្បាប់ស្តីពី សិទ្ធិអ្នកនិពន្ធ ឬច្បាប់ប្រឆាំងទៅនឹងការប្រកួតប្រជែងមិនស្មោះត្រង់ ប្រសិនបើបានបំពេញលក្ខខណ្ឌមួយចំនួន

**សំណួរវាយតម្លៃខ្លួនឯង (SAQ)**

**SAQ ២:** ឧស្សាហករផ្នែកសំលៀកបំពាក់ចង់ដាក់លក់អាវយឺតដែលមានពណ៌ខុសៗគ្នា គឺពណ៌ស ពណ៌ខៀវ និងពណ៌ប្រផេះដែលជាផ្នែកមួយនៃម៉ូដថ្មីរបស់ខ្លួន ។ តើអាវយឺតទាំងនេះអាចការពារដោយគំនូរឧស្សាហកម្មបានដែរ ឬទេ ?

ចូរសរសេរចម្លើយរបស់អ្នក នៅត្រង់នេះ:

ចុចត្រង់នេះដើម្បីមើលចម្លើយ

**SAQ ២: ចម្លើយ**

មិនអាចការពារទេ ដោយសារអាវយឺតមិនបានបង្ហាញពភាពដែលថ្មី ឬភាពដើមណាមួយ ។ ប៉ុន្តែ ប្រសិនបើសម្ភារៈដែលប្រើប្រាស់សម្រាប់ផលិតអាវយឺតគឺថ្មី ឬដើម ឬរូបរាងអាវយឺតគឺថ្មី ឬដើមអាចអនុវត្តគំនូរឧស្សាហកម្មបាន។

## តើកិច្ចការពារមានរយៈពេលប៉ុន្មានដែរ?

ជាថ្មីម្តងទៀត បញ្ហានេះមានការប្រែប្រួលពីប្រទេសមួយទៅប្រទេសមួយ ក៏ប៉ុន្តែរយៈការពារជាទូទៅគឺមានរយៈពេលប្រាំ(០៥)ឆ្នាំ ដោយអាចចុះបញ្ជីសាជាថ្មីបានដែលរយៈពេលសរុបជាអតិបរមាក្នុងប្រទេសជាច្រើនអាចដល់រវាងពីដប់ប្រាំ(១៥)ទៅម្ភៃប្រាំ(២៥)ឆ្នាំ។ រយៈ

©WIPO/OMPI

ពេលអប្បបរមាក្រោមកិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញាគឺ ដប់(១០)ឆ្នាំ ។

ភាគនៃសម្លេង៣ :តើអាចទៅរួចដែររឺទេ គំនូរឧស្សាហកម្ម ការពារក្រោមសិទ្ធិអ្នកនិពន្ធ?

ដោយផ្អែកតាមច្បាប់ពិសេសនិងប្រភេទនៃគំនូរឧស្សាហកម្ម គំនូរមួយអាចត្រូវបានការពារជាស្នាដៃសិល្បៈផងដែរក្រោមច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ ។ នៅក្នុងប្រទេសមួយចំនួនកិច្ចការពារគំនូរឧស្សាហកម្ម និងសិទ្ធិអ្នកនិពន្ធអាចត្រូវបានការពាររួមគ្នា។ នេះមានន័យថា កិច្ចការពារទាំងនេះអាចកើតឡើងដំណាលគ្នា ។ ប៉ុន្តែនៅក្នុងប្រទេសផ្សេងៗទៀត ប្រសិនបើអនុញ្ញាតឱ្យការពារសិទ្ធិអ្នកនិពន្ធនោះត្រូវមានកិច្ចការពាគំនូរឧស្សាហកម្មផលដែរ ។ នេះមានន័យថា នៅពេលដែលម្ចាស់សិទ្ធិជ្រើសយកប្រភេទណាមួយនៃកិច្ចការពារគាត់ត្រូវបាត់បង់ប្រភេទនៃកិច្ចការពារផ្សេងៗទៀត ។

## តើមានកិច្ចការពារផ្សេងទៀតសម្រាបគំនូរឧស្សាហកម្មដែរឬទេ?

ក្រោមកាលៈទេសៈខ្លះ និងនៅក្នុងប្រទេសមួយចំនួន គំនូរឧស្សាហកម្មមួយអាចត្រូវបានការពារក្រោមច្បាប់ស្តីពីអំពើប្រកួតប្រជែងមិនស្មោះត្រង់ផងដែរ ។ ប៉ុន្តែគួរបញ្ជាក់ថាកិច្ចការពារ និងវិធានការដោះស្រាយមានភាពខុសគ្នាតាមទម្រង់ផ្សេងៗនៃកិច្ចការពារ ។

## តើអ្នកអាចទទួលបានកិច្ចការពារគំនូរឧស្សាហកម្មនៅទូទាំងពិភពលោក ដែរឬទេ?

តាមវិធានទូទៅនិងអនុលោមតាមអនុសញ្ញាទីក្រុងប៉ារីស កិច្ចការពារគំនូរឧស្សាហកម្មត្រូវបានកម្រិតត្រឹមប្រទេសដែលស្នើសុំនិងផ្តល់កិច្ចការពារតែប៉ុណ្ណោះ។ នោះត្រូវបានស្នើសុំនិងផ្តល់ឲ្យ ។ ប្រសិនបើកិច្ចការពារត្រូវបានផ្តល់ឱ្យក្នុងប្រទេសជាច្រើនត្រូវមានសំណុំលិខិតស្នើសុំថ្នាក់ជាតិ ( ឬការតម្កល់ទុក )ដោយឡែកពីគ្នាហើយនីតិវិធីជាទូទៅមានលក្ខណៈខុសគ្នានៅក្នុងប្រទេសនីមួយៗ ។ ប៉ុន្តែកិច្ចព្រមព្រៀងទីក្រុងឡាអេ ស្តីពី ការតម្កល់គំនូរឧស្សាហកម្មជាលក្ខណៈអន្តរជាតិបានជួយសម្រួលដល់ដំណើរការនេះ ។

©WIPO/OMPI

# សេចក្តីសង្ខេបស្តីពីកិច្ចការពារគំនូរឧស្សាហកម្ម

គំនូរឧស្សាហកម្ម ជាទិដ្ឋភាពនៃផលិតផលដែលមានអត្ថប្រយោជន៍ដែលមានលក្ខណៈជាការលំអ និងប្រកបដោយសោភ័ណភាព ។ គំនូរឧស្សាហកម្មអាចមានទម្រង់បីខ្នាតដូចជារូបរាង ឬផ្ទៃនៃផលិតផល ឬទម្រង់ពីរខ្នាតដូចជាគំនូរ ខ្សែបន្ទាត់ ឬពណ៌ ។ ដូចទម្រង់ផ្សេងទៀតនៃកម្មសិទ្ធិបញ្ញាដែលគំនូរឧស្សាហកម្មអាចត្រូវបានការពារ ។

តាមរយៈកិច្ចការពារគំនូរឧស្សាហកម្ម ម្ចាស់សិទ្ធិត្រូវបានធានាឱ្យមានសិទ្ធិផ្តាច់មុខប្រឆាំងទៅនឹងលួចចម្លង ឬត្រាប់តាមដែលគ្មានការអនុញ្ញាតដោយភាគីទីពក្នុងកំឡុងពេលជាទូទៅប្រាំ(០៥)ឆ្នាំ ដែលអាចមានលទ្ធភាពបន្តជាថ្មីបាន រហូតដល់រយៈពេលអតិបរមាចាប់ពីដប់ប្រាំ(១៥)ទៅ(២៥)ឆ្នាំ ដោយផ្អែកលើច្បាប់ជាតិណាមួយ។ កិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញាផ្តល់នូវកិច្ចការពារជាអប្បបរមាដប់ឆ្នាំ( ១០)ឆ្នាំ ។

នៅក្នុងប្រទេសជាច្រើន គំនូរឧស្សាហកម្មត្រូវតែចុះបញ្ជីដើម្បីទទួលបានកិច្ចការពារតាមច្បាប់ស្តីពីគំនូរឧស្សាហកម្ម និងជាវិធានទូទៅសម្រាប់ការចុះបញ្ជី គំនូរត្រូវ " **ថ្មី** " និង " **ដើម**" ។ អ្វីដែលកំណត់ភាពថ្មី ឬភាពដើមនៃគំនូរ អាចមានលក្ខណៈខុសគ្នាពីប្រទេសមួយទៅប្រទេសមួយហើយដំណើរការចុះបញ្ជីក៏មានការប្រែប្រួលពីប្រទេសមួយទៅប្រទេសមួយដែរ ។ ជាពិសេស បញ្ហានេះអាចមានការពាក់ព័ន្ធគ្នាថាតើមានការត្រួតពិនិត្យ ឬគ្មានការត្រួតពិនិត្យទម្រង់បែបបទ និងខ្លឹមសារនៃពាក្យស្នើសុំចុះបញ្ជីគំនូ ជាពិសេសដើម្បីកំណត់អំពីភាពថ្មី ឬភាពដើម។ គំនូរឧស្សាហកម្មមួយត្រូវតែអាចផលិតឡើងវិញបានថ្មីតាមមធ្យោបាយឧស្សាហកម្ម។

**អត្ថបទច្បាប់ :**

-កិច្ចព្រមព្រៀងឡាអេស្តីពីការតម្កល់គំនូរឧស្សាហកម្មជាលក្ខណៈអន្តរជាតិ។

-កិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា និងអនុសញ្ញាទីក្រុងប៉ារីស ។

©WIPO/OMPI